**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីថ្លែងអំណរគុណ
## ជូនចំពោះឯកឧត្តម គន់ វិបុល ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ឯកឧត្តមជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ!*

ក្នុងនាមខ្លួនខ្ញុំផ្ទាល់ និងក្រុមគ្រួសារនៃសព សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានគណបក្សប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះឯកឧត្តម ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអគ្គនាយកដ្ឋានពន្ធដារ ដែលបានចូលរួមរំលែកមរណទុក្ខដ៏មហាក្រៀមក្រំក្នុងពិធីបុណ្យសព សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម**។

កាយវិការដ៏ថ្លៃថ្លាឧត្តុង្គឧត្តមរបស់ឯកឧត្តម ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអគ្គនាយកដ្ឋានពន្ធដារ ពិតជាបានសបញ្ជាក់ឱ្យឃើញនូវសមានចិត្តពោរពេញដោយក្តីសោកស្តាយ ស្រណោះអាឡោះអាល័យ និងមនោសញ្ចេតនាគោរពស្រឡាញ់រាប់អានដ៏ស្មោះស្ម័គ្រ និងជ្រាលជ្រៅបំផុតចំពោះ សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ដែលធ្វើឱ្យរូបខ្ញុំ និងក្រុមគ្រួសារនៃសព គ្មានថ្ងៃនឹងបំភ្លេចបានឡើយ។

ខ្លួនខ្ញុំផ្ទាល់ និងក្រុមគ្រួសារនៃសព សូមប្រសិទ្ធពរជ័យជូនចំពោះ ឯកឧត្តម ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអគ្គនាយកដ្ឋានពន្ធដារ សូមទទួលបានពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥
**តំណាងក្រុមគ្រួសារសព**

**សម្តេចក្រឡាហោម ស ខេង**